**ឯកសារស្រាវជ្រាវសង្ខេប**

គណៈកម្មការទី៨ រដ្ឋសភា ទទួលបន្ទុកសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

# ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖ សមិទ្ធផល និងបញ្ហាប្រឈម


ស្រាវជ្រាវដោយ៖ លោក លឹម សុវណ្ណារ៉ា

ដោយមានការចូលរួមពី៖ កញ្ញា វីន មូមូថេ

លោកស្រី វ៉ាន់ ណារី



ខែកុម្ភៈ ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវ ទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការ វិភាគទៅលើ បញ្ហាដែល កំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយ សាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារ មណ្ឌល ឬ ភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់ វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារ យោង ប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយ ឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


**១. សេចក្តីផ្តើម** ........ 1

**២. សមិទ្ធផលនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** ........ 1

២.១. ថ្នាក់ជាតិ ........ 1

២.២. ថ្នាក់ក្រោមជាតិ ........ 2

**៣. បញ្ហាប្រឈម** ........ 3

**៤. សេចក្តីសន្និដ្ឋាន** ........ 6

**ឯកសារយោង** ........ 8

## ១. សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា មានការរាយការណ៍ថា ប្រជាពលរដ្ឋវ័យក្មេងចំនួនជាង ៣០០.០០០ នាក់ចូលប្រឡូកក្នុងទីផ្សារការងាររៀងរាល់ឆ្នាំ។ ចំនួននេះរំពឹងថានឹងមានការកើនឡើងដល់៤០០.០០០ នាក់នាពេលអនាគតដ៏ឆាប់ខាងមុខ។[1] ការបង្កើតការងារសម្រាប់អ្នកទាំងនោះ គឺជាបញ្ហាប្រឈមមួយសម្រាប់អ្នកធ្វើគោលនយោបាយនៅក្នុងប្រទេសកម្ពុជា។ អនាគតសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកទៅលើកម្លាំងការងាររបស់ពលរដ្ឋវ័យក្មេង។ ប្រការនេះទាមទារឲ្យមានការអប់រំដែលកាន់តែពាក់ព័ន្ធ និងឆ្លើយតប និងប្រព័ន្ធបណ្តុះបណ្តាលជាច្រើនថែមទៀត ដើម្បីផ្តល់ដល់សិស្ស នូវចំណេះដឹង និងជំនាញដើម្បីក្លាយជាកម្លាំងការងារដែលប្រកបដោយផលិតភាព។[2] រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវសារៈ-សំខាន់នៃការមានកម្លាំងការងារដែលមានជំនាញ ជាមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចដ៏រឹងមាំ និងប្រកបដោយភាពប្រកួតប្រជែង។

## ២. សមិទ្ធផលនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

### ២.១. ថ្នាក់ជាតិ

នៅក្នុងខែធ្នូ ឆ្នាំ២០១១ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានគូសបង្ហាញគោលនយោបាយជាអាទិភាពប្រាំ នៅក្នុងការលើកកម្ពស់គុណភាព និងការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តោតការយកចិត្តទុកដាក់លើតួនាទីនៃការអភិវឌ្ឍជំនាញ កាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋក្រីក្រតាមជនបទ និងគាំទ្រដល់ការអភិវឌ្ឍបុគ្គលម្នាក់ៗដោយផ្តល់នូវជំនាញ។ គោលនយោបាយទាំងប្រាំរួមមាន៖

(១) ផ្សារភ្ជាប់ការបណ្តុះបណ្តាលទៅនឹងតម្រូវការទីផ្សារ
(២) ធានានូវគុណភាពនៃវគ្គបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ផលិតភាព
(៣) ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន
(៤) ធានានូវសមភាពក្នុងវគ្គបណ្តុះបណ្តាល
(៥) លើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។[3]

ជាង២ទស្សវត្សន៍កន្លងមកនេះ មានសិស្សចំនួនជាង ៨៦ ៣ាន់ នាក់បានចុះឈ្មោះនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ហើយជាង ៨០% នៃសិស្សទាំងនោះ មកពីតំបន់ជនបទ ហើយ ៥៥% នៃអ្នកចុះឈ្មោះទាំងនោះ គឺជាស្ត្រី។ ជាការគួរឲ្យកត់សម្គាល់ អត្រានៃការបោះបង់ការសិក្សា មានកម្រិតទាប (៤,៥%)។ ក្នុងចំណោម គ្រឹះស្ថានសរុបចំនួន ៣៨ គ្រឹះស្ថានចំនួន ៨

មានទីតាំងនៅភ្នំពេញ និង៣០ផ្សេងទៀត មានទីតាំងនៅតាមបណ្តាខេត្តផ្សេងៗទូទាំងប្រទេស។ គ្រូបណ្តុះបណ្តាលសរុបមានចំនួន ១.៧៨៤នាក់ ក្នុងនោះស្ត្រីមានចំនួន ៧២១នាក់(៤០%)។

**តារាងទី១៖ គ្រឹះស្ថាន សិស្ស និងបុគ្គលិកបណ្តុះបណ្តាល**

| ទីតាំង | ចំនួនវិទ្យាស្ថាន[4] | ការចុះឈ្មោះ | | បោះបង់ការសិក្សា | | គ្រូបណ្តុះបណ្តាល | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ទូទាំងប្រទេស | 38 | 86,616 | 47,669 | 3,932 | 1,796 | 1,784 | 721 |
| ភ្នំពេញ | 8 | 15,168 | 6,325 | 874 | 235 | 254 | 135 |
| ខេត្ត | 30 | 71,448 | 41,344 | 3,058 | 1,561 | 1,530 | 586 |

*ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ស្ថិតិអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ខែសីហា ឆ្នាំ២០១៤)*

ដើម្បីយល់អំពីទំនាក់ទំនងរវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការរកប្រាក់ចំណូល ចាំបាច់ត្រូវពិនិត្យភាគរយនៃអ្នកដែលបញ្ចប់ការបណ្តុះបណ្តាល ហើយបានទទួលការងារ។ អត្រាទទួលបានការងារធ្វើសរុបបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល មានកម្រិតខ្ពស់ល្អ ពោលគឺ ៦៦%។ អត្រាទទួលបានការងារធ្វើកើនរហូតដល់ ៧៥% សម្រាប់អ្នកបានបញ្ចប់ការបណ្តុះបណ្តាលជាស្ត្រី។ អ្នកដែលបញ្ចប់ការបណ្តុះបណ្តាលនៅតាមខេត្តមានភាពប្រសើរជាងអ្នកបញ្ចប់ការបណ្តុះបណ្តាលនៅភ្នំពេញ។ ក្នុងពេលដែល ៧៣% នៃអ្នកបញ្ចប់ការបណ្តុះបណ្តាលនៅតាមខេត្តរកការងារបាន មានតែ ៣៣% នៃអ្នកបញ្ចប់ការបណ្តុះបណ្តាលនៅភ្នំពេញអាចរកការងារបាន។

**តារាងទី២៖ ទទួលបានការងារបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល (ទូទាំងប្រទេស)**

| ទីតាំង | ចំនួនគ្រឹះស្ថាន | ចុះឈ្មោះ-បោះបង់ការសិក្សា | | ទទួលបានការងារបន្ទាប់ពីបញ្ចប់ការសិក្សា | | ភាគរយ (%) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ទូទាំងប្រទេស | 38 | 82,684 | 45,873 | 54,919 | 34,270 | 66% | 75% |
| ភ្នំពេញ | 8 | 14,294 | 6,090 | 4,677 | 1,766 | 33% | 30% |
| ខេត្ត | 30 | 68,390 | 39,783 | 50,242 | 32,504 | 73% | 82% |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយពឹងផ្អែកលើស្ថិតិអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សីហា ២០១៤)។*

## ២.២. ថ្នាក់ក្រោមជាតិ

ខេត្តចំនួន ៤ ដែលជាគោលដៅនៃដំណើរទស្សនកិច្ចរបស់គណៈកម្មការទី៨ នៃរដ្ឋសភា គឺខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងខេត្តក្រចេះ ដែលខេត្តនីមួយៗមានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលចំនួន ១។ ទោះជាយ៉ាងណាក៏ដោយ ខេត្តក្រចេះនាំមុខគេក្នុងចំណោមខេត្តទាំង៤ លើអត្រានៃការ

ចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួន (២.៦៥៤) បន្ទាប់មកខេត្តរតនគីរី (១.៥០០)។ ខេត្តស្ទឹងត្រែងមានចំនួនតែ ២៦០ នាក់ប៉ុណ្ណោះដែលបានចុះឈ្មោះក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**តារាងទី៣៖ គ្រឹះស្ថាន សិស្ស និងគ្រូបណ្តុះបណ្តាលតាមខេត្ត**

| ខេត្ត | ចំនួនវិទ្យាស្ថាន | សិស្ស | | | | គ្រូបណ្តុះបណ្តាល | |
|---|---|---|---|---|---|---|---|
| | | ការចុះឈ្មោះ | | ការបោះបង់ការសិក្សា | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| មណ្ឌលគីរី | 1 | 376 | 184 | 12 | 1 | 13 | 0 |
| រតនគីរី | 1 | 1,500 | 627 | 283 | 125 | 15 | 6 |
| ស្ទឹងត្រែង | 1 | 260 | 156 | 0 | 0 | 23 | 8 |
| ក្រចេះ | 1 | 2,654 | 1,724 | 27 | 16 | 36 | 2 |
| ខេត្តផ្សេងៗ | 26 | 66,658 | 38,646 | 2,736 | 1,419 | 1,443 | 570 |
| ភ្នំពេញ | 8 | 15,168 | 6,325 | 874 | 235 | 254 | 135 |
| ទូទាំងប្រទេស | 38 | 86,616 | 47,662 | 3,932 | 1,796 | 1,784 | 721 |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយពឹងផ្អែកលើស្ថិតិអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សីហា ២០១៤)។*

## ៣. បញ្ហាប្រឈម

បើទោះបីជាការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានទទួលនូវភាពជោគជ័យក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួន ដែលរួមមាន៖

(១) មិនអាចទាក់ទាញបានចំនួនគ្រប់គ្រាន់ នៃអ្នកដែលត្រូវការបំផុត នូវការបណ្តុះបណ្តាលផ្នែកជំនាញ ដូចជាអ្នកគ្មានការងារធ្វើ អ្នកមានការងារធ្វើមិនគ្រប់គ្រាន់ ក្រុមដែលជួបការលំបាក (ពិការភាព) និងក្រុមដែលបានបោះបង់ការសិក្សា។

(២) ខ្វះខាតគ្រូអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានសមត្ថភាព

(៣) ការគ្រប់គ្រង និងដឹកនាំនៅមានកម្រិត

(៤) មានភាពទន់ខ្សោយក្នុងការទំនាក់ទំនងល្អ និងការរកទីផ្សារ

(៥) មិនមានសម្ភារៈបណ្តុះបណ្តាល ឬសម្ភារៈសិក្សា គ្រឿងបរិក្ខា គ្រប់គ្រាន់

(៦) មិនមានសមភាពក្នុងការចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថានបណ្តុះបណ្តាល

(៧) ភាពជាដៃគូរវាងរដ្ឋ និងឯកជនមានកម្រិត។[5]

យោងតាម ADB បញ្ហាប្រឈមចម្បងទៅនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមមាន៖

(១) មិនមានការផ្តោតលើសហគ្រិនភាព

(២) ខ្វះខាតនូវប្រព័ន្ធធានានូវគុណភាព និងព័ត៌មានទីផ្សារការងារ

(៣) មានភាពទន់ខ្សោយក្នុងការត្រួតពិនិត្យកម្មវិធីសិក្សានៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថាន

(៤) ទំនាក់ទំនងរវាងសហគ្រាស និងក្រុមហ៊ុននៅមានកម្រិត

(៥) ខ្វះឱកាសចូលរួមវគ្គបណ្តុះបណ្តាលផ្លូវការនៅតាមជនបទ

(៦) ខ្វះសិល្បៈ និងភាពបត់បែនក្នុងការផ្តល់វគ្គបណ្តុះបណ្តាល

(៧) មិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។[6]

## *ពីការអនុវត្តតាមរបៀបផ្គត់ផ្គង់ទៅជាការឆ្លើយតបទៅតាមតម្រូវការ*

សំណួរគោលនយោបាយសំខាន់ពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគឺ៖ តើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគួរជាការអនុវត្តតាមរបៀបផ្គត់ផ្គង់ (Supply driven) ឬ ជាការឆ្លើយតបទៅនឹងតម្រូវការ (Demand Driven)? ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា គឺជាយន្តការអនុវត្តតាមរបៀបផ្គត់ផ្គង់ (Supply Driven)។ ការអនុវត្តតាមរបៀបផ្គត់ផ្គង់មានន័យថា គ្រឹះស្ថានបណ្តុះបណ្តាលនៅតែផ្តល់ការបណ្តុះបណ្តាលលើជំនាញដដែលៗ ដោយមិនបានគិតដល់តម្រូវការនៃសហគ្រាស និងទីផ្សារការងារ។[7] ប្រព័ន្ធនៃការបណ្តុះបណ្តាលតាមរយៈរបៀបផ្គត់ផ្គង់ទៅនឹងតម្រូវការ (Supply-Demand Driven) ខុសពីការអនុវត្តតាមរបៀបផ្គត់ផ្គង់ (Supply driven) ទៅចំណុចទាំងនេះ៖ ការប្រើព័ត៌មានត្រលប់ពីទីផ្សារ អភិបាលកិច្ច ការគ្រប់គ្រងគ្រឹះស្ថាន ការលើកទឹកចិត្ត កម្មវិធីបណ្តុះបណ្តាល និងគ្រូបង្រៀន។ តារាងខាងក្រោមបង្ហាញនូវភាពខុសគ្នារវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមរបៀបផ្គត់ផ្គង់ និងការបណ្តុះបណ្តាលឆ្លើយតបនឹងតម្រូវការ។

**តារាង៤៖ លក្ខណៈនៃប្រព័ន្ធនៃការបណ្តុះបណ្តាលតាមរបៀបផ្គត់ផ្គង់ និងឆ្លើយតបនឹងតម្រូវការ**

| ផ្នែក | ផ្តោតលើការផ្គត់ផ្គង់ | | ផ្តោតលើតម្រូវការ |
|---|---|---|---|
| ព័ត៌មានត្រលប់ពីទីផ្សារ | មិនឆ្លើយតបទៅនឹងទីផ្សារ | ↔ | ពឹងផ្អែកលើព័ត៌មានត្រលប់ពីទីផ្សារ។ ឧ. ការអង្កេតទៅលើអ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាល តើពួកគេធ្វើអ្វីក្រោយបញ្ចប់ការបណ្តុះបណ្តាល |
| អភិបាលកិច្ច | មានកិច្ចការរដ្ឋបាលច្រើន និងគ្រប់ដណ្តប់ដោយរដ្ឋ | ↔ | ចូលរួមដោយអ្នកប្រើប្រាស់ចុងក្រោយពោល គឺនិយោជក |
| ការគ្រប់គ្រងគ្រឹះស្ថាន | មានគណនេយ្យភាពតិចតួចចំពោះលទ្ធផល | ↔ | មានគណនេយ្យភាពប្រកបដោយនិរន្តភាព ចំពោះលទ្ធផល |
| ការលើកទឹកចិត្ត | គោរពគោលការណ៍ និងយកចិត្តតែអ្នកទទួលបន្ទុកចំណាយ | ↔ | បង្កើនចំណូលដោយការផ្តល់សេវានៅក្នុងទីផ្សារ |
| កម្មវិធីបណ្តុះបណ្តាល | មិនប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ | ↔ | ប្រែប្រួលទៅតាមតម្រូវការទីផ្សារ |
| គ្រូបង្រៀន | ពេញម៉ោង ជាញឹកញាប់ជាមន្ត្រីរាជការ ឬអ្នកដែលមានកិច្ចសន្យាការងាររយៈពេលវែង ការចាកចេញពីការងារមានកម្រិតទាប ចំណាយពេលធ្វើការនៅតែក្នុងគ្រឹះស្ថាន | ↔ | កិច្ចសន្យាការងាររយៈពេលខ្លី ប្រើប្រាស់បុគ្គលិកមិនធ្វើការពេញម៉ោង ជួនកាលមានការចាកចេញពីការងារញឹកញាប់ ការធ្វើទស្សនកិច្ចនៅតាមសហគ្រាសដើម្បីសិក្សាជំនាញដែលមានតម្រូវការ |
| សិក្ខាកាម | ទទួលការបណ្តុះបណ្តាលតែក្នុងស្ថាប័ន | ↔ | អនុវត្តការងារ និងកម្មសិក្សានៅក្នុងឧស្សាហកម្ម |
| ទីតាំង និងគ្រឿងបរិក្ខា | មានស្រាប់ | ↔ | សម្របតាមស្ថានការណ៍ អាចជួល |
| ថវិកា | ត្រូវបានធានា មិនខ្វល់ពីការបំពេញការងារ | ↔ | ត្រូវតែរក |

*ប្រភព៖ ADB 2009, p 15.* [8]

តើអ្វីទៅជាមធ្យោបាយក្នុងការផ្លាស់ប្តូរពី ការផ្តោតលើការបណ្តុះបណ្តាលរបៀបផ្គត់ផ្គង់ ឲ្យទៅជាប្រព័ន្ធនៃការបណ្តុះបណ្តាលដែលផ្តោតលើតម្រូវការទីផ្សារ? ខាងក្រោមនេះ គឺជាជំហានមួយចំនួនដែលអាចប្រើប្រាស់បាន៖[9]

- ផ្តោតលើនយោជកក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច។
- ត្រូវរៀបចំឲ្យមានការអង្កេតលើអ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាល តើពួកគេធ្វើអ្វីក្រោយបញ្ចប់ការបណ្តុះបណ្តាល និងផ្លាស់ប្តូរកម្មវិធីបណ្តុះបណ្តាលទៅតាមលទ្ធផលនៃការអង្កេតនោះ។
- ចំណាយលើអ្នករៀបចំកម្មវិធីសិក្សាដើម្បីឲ្យកម្មវិធីសិក្សានេះមានការឆ្លើយតបទៅនឹងទីផ្សារដែលពឹងផ្អែកលើស្តង់ដារការងារ។
- ធ្វើការចំណាយទៅតាមការបំពេញការងារធៀបទៅនឹងការកំណត់ជាមុននូវបរិមាណ និងគុណភាព។ ឧ. តាមសិក្ខាកាម និងពេលវេលា តាមចំនួនអ្នកបញ្ចប់ការបណ្តុះបណ្តាលដែលមានសមត្ថភាពតាមស្តង់ដារ ឬក៏ទៅតាមចំនួនអ្នកដែលបញ្ចប់ការការបណ្តុះបណ្តាលហើយមានការងារធ្វើ។
- ធ្វើឲ្យអ្នកគ្រប់គ្រង និងស្ថាប័នមានគណនេយ្យភាពទៅនឹងលទ្ធផលចំពោះក្រុមប្រឹក្សាភិបាលដែលភាគច្រើនជានយោជក
- តម្រូវឲ្យថវិកាទាំងអស់ ឬភាគខ្លះ ត្រូវតែរកបានមកពីទីផ្សារ និងធ្វើឲ្យស្ថាប័នមានស្វ័យភាព និងមានសមត្ថភាពធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ដោយមានវិធានការណ៍សមស្របក្នុងការគ្រប់គ្រងហានិភ័យ និងគណនេយ្យ។

## ៤. សេចក្តីសន្និដ្ឋាន

ជាងពីរទសវត្សរ៍ កម្ពុជាបានទទួលនូវលទ្ធផលល្អនៅក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ការចុះឈ្មោះ មានស្ថិរភាពទូទាំងប្រទេស។ អំពីការងារវិញ សិស្សជាស្ត្រីដែលបានបញ្ចប់ការបណ្តុះបណ្តាល មាននិន្នាការប្រសើរជាងសិស្សជាបុរសដែលបានបញ្ចប់ការបណ្តុះបណ្តាល ហើយសិស្សដែលបញ្ចប់ការបណ្តុះបណ្តាលនៅតាមបណ្តាខេត្តមាននិន្នាការប្រសើរជាងសិស្សដែលបញ្ចប់ការបណ្តុះបណ្តាលនៅភ្នំពេញ។ ក្នុងន័យនេះ ប្រព័ន្ធការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គួរត្រូវបានពង្រីក ដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើសិស្សជាស្ត្រី និងនៅតាមជនបទ។ នៅពេលដែលប្រទេសកំពុងឈានចូលដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច (សហគមន៍សេដ្ឋកិច្ចអាស៊ានមានដំណើរការ ការឈានចូលជាប្រទេសដែលមានចំណូលទាបមធ្យមក្នុងពេលឆាប់ៗ និងការវិវឌ្ឍផ្សេងៗទៀតនៃសសរស្តម្ភសេដ្ឋកិច្ច និងឧស្សាហ-

កម្ម) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានរំពឹងថានឹងដើរតួនាទីកាន់តែសំខាន់ក្នុងការបំពេញនូវកង្វះខាតជំនាញ។

ទោះបីជាយ៉ាងណាក៏ដោយ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមានកម្រិត ដោយទទួលបានសិស្សចំនួនត្រឹមតែ ៤,០០០ នាក់ក្នុងមួយឆ្នាំ។ ការពង្រីកប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺជាបញ្ហាមួយដែលត្រូវចូលរួមដោះស្រាយពីគ្រប់ភាគីពាក់ព័ន្ធ។ បន្ថែមលើការពង្រីកនេះ យន្តការនៃការផ្លាស់ប្តូរពីការអនុវត្តតាមរបៀបផ្គត់ផ្គង់ ឲ្យទៅជាយន្តការឆ្លើយតបនឹងតម្រូវការ គឺជាការអនុវត្តមួយដែលត្រូវបានអនុវត្តដោយប្រទេសកំពុងអភិវឌ្ឍមួយចំនួន។ ការផ្លាស់ប្តូរពីការអនុវត្តតាមរបៀបផ្គត់ផ្គង់ឲ្យទៅជាយន្តការឆ្លើយតបនឹងតម្រូវការ នឹងធ្វើឲ្យការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានលក្ខណៈឆ្លើយតបទៅនឹងទីផ្សារការងារ ដែលនឹងលើកកម្ពស់ដល់ការស្វែងរកការងាររបស់សិស្សផងដែរ។

## ឯកសារយោង

---

[1] UNITED NATIONS COUNTRY TEAM May 2009 Situation Analysis of Youth in Cambodia: "Youth are not the creators of problems in society; rather, it society that bring the problems being faced by youth". Phnom Penh United Nation,.

[2] ASIAN DEVELOPMENT BANK 2014 Cambodia: Country Partnership Strategy (2014-2018). Phnom Penh Asian Development Bank,.

[3] UNESCO 2013. Policy Review of TVET in Cambodia Bangkok, Thailand: UNESCO.

[4] Number of institutions: total number of public TVET institution which have a real location and their management structure recognized by the MOLVT.

[5] TEP, O. 2011. Current Status & Future TVET Policy Ministry of Labor and Vocational Training.

[6] ASIAN DEVELOPMENT BANK 2014 Cambodia: Country Partnership Strategy (2014-2018). Phnom Penh Asian Development Bank,.p.2

[7] ASIA DEVELOPMENT BANK 2009. Good Practice in Technical and Vocational Education and Training. Philippines: Asian Development Bank,.p.13.

[8] Ibid. p.15.

[9] Ibid.pp.15-16.